# ព្រះរាជក្រឹត្យ

នស/រកត/០១១៨/៥៤២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៥ នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការបោះឆ្នោតជ្រើសតាំងរចនាសម្ព័ន្ធថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាព រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១១១០ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣ ស្តីពីការតែងតាំងឯកឧត្តម និងលោកជំទាវ ជាទីប្រឹក្សាជាន់ខ្ពស់ ក្នុងនីតិកាលទី៥ នៃរដ្ឋសភា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៤/១១១៥ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការតែងតាំងជាទីប្រឹក្សាជាន់ខ្ពស់ ក្នុងនីតិកាលទី៥ នៃរដ្ឋសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា។

## ត្រាស់បង្គាប់

**មាត្រា១** : បញ្ចប់មុខតំណែងឯកឧត្តមជាទីប្រឹក្សាជាន់ខ្ពស់ ក្នុងនីតិកាលទី៥ នៃរដ្ឋសភា ចំនួន ០៦រូប:

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ឡឹម** | **ស៊ីថន** | មានឋានៈស្មើ **រដ្ឋមន្ត្រី** |
| ២- ឯកឧត្តម | **ពេជ្រ** | **គឹមស្រ៊ាង** | មានឋានៈស្មើ **រដ្ឋមន្ត្រី** |
| ៣- ឯកឧត្តម | **សុភ** | **មិន** | មានឋានៈស្មើ **រដ្ឋមន្ត្រី** |
| ៤- ឯកឧត្តម | **សារី** | **កោសល្យ** | មានឋានៈស្មើ **រដ្ឋមន្ត្រី** |
| ៥- ឯកឧត្តម | **ពៅ** | **សាមី** | មានឋានៈស្មើ **រដ្ឋមន្ត្រី** |
| ៦- ឯកឧត្តម | **អ៊ុក** | **ដាមរី** | មានឋានៈស្មើ **រដ្ឋមន្ត្រី** |

**មាត្រា២** : មាត្រា១ លេខរៀងទី៥,៦,១៣,១៥ និង២៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១១១០ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣ និងមាត្រា១ លេខរៀងទី២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩១៤/១១១៥ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៤ ត្រូវទុកជានិរាករណ៍។

**មាត្រា៣** : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ៨៧ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

ថ្ងៃចន្ទ ៦កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ពរ.១៨០១.០៥៤២

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១១ ខែមករា ឆ្នាំ២០១៨*

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**